00723639 E51/14

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 08 / 08 / 2011
ម៉ោង (Time/Heure): 11:45
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

ចំពោះមុខ: ចៅក្រម **និល ណុន** ជាប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម **យ៉ា សុខន**
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម **ធូ មណី**

កាលបរិច្ឆេទ: ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១
ភាសាដើម: ខ្មែរ/អង់គ្លេស/បារាំង

ចំណាត់ថ្នាក់ឯកសារ: សាធារណៈ

# សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិតលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក នៅនឹងច្បាប់រដ្ឋធម្មនុញ្ញ

**សហព្រះរាជអាជ្ញា**
ជា លាង
Andrew CAYLEY

**ជនជាប់ចោទ**
នួន ជា

**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី**
ពេជ អង្គ
Elisabeth SIMONNEAU FORT

**មេធាវីជនជាប់ចោទ**
សុន អរុណ
Michiel PESTMAN
Victor KOPPE

## ១. សេចក្តីផ្តើម

១. នៅក្នុងអញ្ញត្រកម្មរួមបញ្ចូលគ្នារបស់ខ្លួន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ លោក នួន ជា ("ជនជាប់ចោទ") អះអាងថា ការអនុម័តលើវិធានផ្ទៃក្នុងពីដើមដំបូង និងវិសោធនកម្មក្រោយៗមកទៀតទៅលើវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក គឺ "ផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញ និង លើសពីសមត្ថកិច្ច (*ultra vires*)"[១]។ គាត់បានអះអាងថែមទៀតថា ការបន្តអនុវត្តវិធានជាក់លាក់មួយចំនួន ក៏ដូចជា ការអនុវត្តដីការបស់អង្គជំនុំជម្រះ "បង្គាប់ឲ្យភាគីដាក់នូវសម្ភារៈដើម្បីរៀបចំសវនាការ" ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ("ដីកាបង្គាប់ឲ្យរៀបចំ") រំលោភដល់សិទ្ធិរបស់ នួន ជា ក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់ និងការជំនុំជម្រះក្តីដោយយុត្តិធម៌[២]។ ជនជាប់ចោទស្នើសុំទាញហេតុផលដោយផ្ទាល់មាត់ថែមទៀតស្តីពីបញ្ហាទាំងអស់នេះ នៅពេលសវនាការបឋម[៣]។

២. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា ("ក.ស.ព") បានឆ្លើយតបដាច់ដោយឡែកពីគ្នាទៅនឹងអញ្ញត្រកម្មរបស់គ្រប់ភាគីទាំងអស់ នៅថ្ងៃទី ០៧ និងថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ។ សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី និងសហព្រះរាជអាជ្ញា បានជំទាស់ទៅនឹងអញ្ញត្រកម្មនេះ (សុពលភាពនៃវិធានផ្ទៃក្នុង) ទាំងលើមូលដ្ឋាននៃភាពអាចទទួលយកបានផង និងមូលដ្ឋាននៃខ្លឹមសារផង[៤]។

## ២. អំណះអំណាង

៣. ជនជាប់ចោទអះអាងថា អញ្ញត្រកម្មរបស់ខ្លួន គឺអាចទទួលយកបាន ដោយផ្អែកតាមវិធាន

---

[១] អញ្ញត្រកម្មរួមបញ្ចូលគ្នា ឯកសារ E51/3 ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ("អញ្ញត្រកម្មរួមបញ្ចូលគ្នា") កថាខណ្ឌ ៣។

[២] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៣។ ដីកាបង្គាប់ឲ្យភាគីដាក់នូវសម្ភារៈដើម្បីរៀបចំសវនាការ ឯកសារ E9 ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ("ដីកាបង្គាប់ឲ្យរៀបចំ")។

[៣] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៣៩។

[៤] ចម្លើយតបរួមរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំពោះសារណារបស់ក្រុមភាគីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មបឋម តាមវិធាន ៨៩ ឯកសារ E51/5/4 ចុះថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី") កថាខណ្ឌ ៣២។ ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញាចំពោះសារណារបស់ក្រុមភាគីការពារក្តីទាក់ទងនឹងអញ្ញត្រកម្មបឋម តាមវិធាន ៨៩ ឯកសារ E51/5/3/1 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១១ ("ចម្លើយតបរបស់ ក.ស.ព") កថាខណ្ឌ ៨០ ដល់ ៩០។

៨៩(១)(ក)(គ)[៥]។ ពាក់ព័ន្ធនឹងខ្លឹមសាររបស់វា ជនជាប់ចោទអះអាងថា អ.វ.ត.ក គឺជាតុលាការកម្ពុជាដែលត្រូវបានបង្កើតឡើងអនុលោមតាមបទដ្ឋានគតិយុត្តដែលត្រូវបានយល់ព្រម និងអនុម័តដោយអង្គនីតិបញ្ញត្តិកម្ពុជា។ ច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជាប្រគល់អំណាចក្នុងការតាក់តែងច្បាប់ទៅឱ្យអង្គនីតិបញ្ញត្តិជាតិ និងហាមមិនឱ្យមានការផ្ទេរអំណាចនេះទៅឱ្យអង្គផ្សេងទៀតទេ។ មាត្រា ១២(១) នៃច្បាប់ កិច្ចព្រមព្រៀង អ.វ.ត.ក អនុញ្ញាតឱ្យ អ.វ.ត.ក ស្វែងរក ការណែនាំនៅក្នុងបទដ្ឋានអន្តរជាតិ "នៅពេលណាមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬនៅពេលណាមានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរ-ជាតិ"។ ទោះបីជាយ៉ាងណាក៏ដោយ វិធានផ្ទៃក្នុងថែងលើសពីការកំណត់ទាំងនេះ ហើយដូច្នេះលើសពីសមត្ថកិច្ច (*ultra vires*)[៦]។ ជនជាប់ចោទ នៅតែលើកឡើងថែមទៀតថា មាត្រា ១២(១) ផ្តល់សិទ្ធិឱ្យ អ.វ.ត.ក យោងទៅបទដ្ឋានអន្តរជាតិទៅតាមតម្រូវការក្នុងករណីនីមួយៗ ប៉ុន្តែមិនមែន មានន័យថាឱ្យបើកកិច្ចប្រជុំពេញអង្គដើម្បីបង្កើតប្រព័ន្ធវិធាន ដ៏ទូលំទូលាយមួយនោះឡើយ[៧]។ ជនជាប់ចោទអះអាងថែមទៀតថា ការបន្តអនុវត្តវិធានផ្ទៃក្នុងបង្កើតបានជាការរំលោភលើសិទ្ធិក្នុងការទទួលបាននូវសច្ចភាពផ្លូវច្បាប់[៨]។ ដោយសារដីកាបង្គាប់ឱ្យរៀបចំនេះផ្អែកលើវិធានទាំងនេះ ដីកានេះគ្មានអំណាចគតិយុត្ត និងគួរតែត្រូវប្រកាសថាជាមោឃៈ[៩]។

៤. ជាការឆ្លើយតប ក.ស.ព និងក្រុមដើមបណ្តឹងរដ្ឋប្បវេណី អះអាងថា សំណើសុំនេះមិនស្ថិតក្នុងក្របខណ្ឌនៃវិធាន ៨៩(១) នៃវិធានផ្ទៃក្នុងឡើយ ហេតុដូច្នេះហើយមិនអាចទទួលយកសំណើសុំនេះបានទេ[១០]។ ក.ស.ព លើកឡើងថែមទៀតថា ជារួម ក្របខណ្ឌច្បាប់ អ.វ.ត.ក ផ្តល់នូវអំណាចស្របច្បាប់សម្រាប់កិច្ចនីតិវិធីដែលធ្វើឡើងដោយ អ.វ.ត.ក។ ពាក់ព័ន្ធនឹង ចំណុចនេះ ដីកាបង្គាប់ឱ្យរៀបចំនេះគ្រាន់តែណែនាំឱ្យភាគីនានាផ្តល់ព័ត៌មានត្រៀមរៀបចំមុនពេលសវនា-ការប៉ុណ្ណោះ ហើយលោក នួន ជា បានលើកឡើងរួចហើយថា ដីកាបង្គាប់នេះ ជារួម គឺស្រប

---

[៥] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៣ និង៣៨។

[៦] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ២០ ដល់ ២៥, ៣៣ ដល់ ៣៤, ៦៦ ដល់ ៦៩។

[៧] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៣៥, ៦៦ ដល់៦៩។

[៨] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៧១។

[៩] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ៧២។

[១០] ចម្លើយតបរបស់ភាគីដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៣២។ ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៨១។

00723642



ទៅនឹងកាតព្វកិច្ចរបស់ខ្លួននៅក្រោមច្បាប់កម្ពុជា[១១]។ ការយោងជាក់លាក់តែមួយគត់ទៅវិធានផ្ទៃក្នុងនៅក្នុងដីកាបង្គាប់ឲ្យរៀបចំ ពាក់ព័ន្ធនឹងលក្ខខណ្ឌតម្រូវឲ្យភាគីនានាធ្វើជាបញ្ជីមួយស្ដីពីអង្គហេតុទាំងឡាយណាដែលមិនជំទាស់។ ដោយសារតែលោក នួន ជា ពុំចាំបាច់ត្រូវឯកភាពទៅនឹងអង្គហេតុណាមួយទេនោះ ការយោងនេះពុំមានផលប៉ះពាល់អ្វីឡើយ[១២]។

## ៣. សំអាងហេតុ

៥. វិធាន ៨៩(១)(គ) នៃវិធានផ្ទៃក្នុង ចែងពីអញ្ញត្រកម្មទាក់ទងទៅនឹង "មោឃភាពនីតិវិធីដែលត្រូវបានធ្វើបន្ទាប់ពីមានដីកាដំណោះស្រាយ"។ ដីកាដំណោះស្រាយនៅក្នុងរឿងក្ដីនេះត្រូវបានដាក់នៅថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០១០។ ហេតុដូច្នេះ ការអនុម័តវិធានផ្ទៃក្នុង ដែលបានធ្វើឡើងនៅខែ មិថុនា ឆ្នាំ ២០០៧ មិនមែនជា "នីតិវិធី" ដែលស្ថិតនៅក្នុងអត្ថន័យនៃវិធាន ៨៩(១)(គ) នោះទេ។ ហេតុដូច្នេះ ការជំទាស់ទៅនឹងនីត្យានុកូលភាពនៃវិធានទាំងនេះ មិនអាចទទួលយកថាជាអញ្ញត្រកម្មបានឡើយ។

៦. ខ្លឹមសារនៃការជំទាស់របស់ នួន ជា ទៅនឹងវិធានផ្ទៃក្នុងគឺ គ្មានមូលដ្ឋានគ្រប់គ្រាន់ទេ។ ពុំមានបញ្ញត្តិណាមួយនៅក្នុងមាត្រា ១២(១) ឬនៅក្នុងមាត្រាផ្សេងទៀតនៃកិច្ចព្រមព្រៀង អ.វ.ត.ក ហាមឃាត់មិនឲ្យមានការអនុម័តបទដ្ឋាននីតិវិធីនានាដែលធ្វើឡើងដោយកិច្ចប្រជុំពេញអង្គដែលត្រូវបានធ្វើឡើងដើម្បីគោលបំណងនេះឡើយ[១៣]។

៧. គោលបំណងរបស់វិធានផ្ទៃក្នុងគឺដើម្បីបង្រួមនីតិវិធីកម្ពុជាជាធរមាន និងដើម្បីបំពេញបន្ថែមដោយបទដ្ឋានអន្តរជាតិ ក្នុងករណីចាំបាច់ និងសមស្រប។ ដូចដែលអង្គបុរេជំនុំជម្រះបានលើកឡើងកាលពីពេលមុនរួចហើយថា សវនាការនៅ អ.វ.ត.ក ខុសគ្នាយ៉ាងខ្លាំងពីរឿងក្ដីធម្មតានៅចំពោះមុខតុលាការកម្ពុជា[១៤]។ តុលាការអន្តរជាតិផ្សេងៗទៀតដែលជំនុំជម្រះរឿងក្ដីប្រហាក់ប្រហែលគ្នាទៅនឹងរឿងក្ដីនៅចំពោះមុខ អ.វ.ត.ក ក៏បានអនុម័តវិធានស្ដីពីនីតិវិធី និងភស្តុតាងផងដែរ ដោយកែសម្រួលឲ្យស្របទៅតាមលក្ខខណ្ឌតម្រូវនៃការជំនុំជម្រះលើករណី

---

[១១] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៨៨ ដល់៨៩។

[១២] ចម្លើយតបរបស់ ក.ស.ព កថាខណ្ឌ ៨៩។

[១៣] មាត្រា ១២(១) នៃកិច្ចព្រមព្រៀង អ.វ.ត.ក ចែងថា "ការណែនាំអាចត្រូវបានស្វែងរក" នៅក្នុងនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ។

[១៤] សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព (សាធារណៈ) ឯកសារ D55/1/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១៤។

ព្រហ្មទណ្ឌអន្តរជាតិដ៏ស្មុគ្រស្មាញ។ ដូចដែលជនជាប់ចោទបានទទួលស្គាល់ហើយថា គណៈកម្មាធិការនីតិវិធី និងវិធានផ្ទៃក្នុង បានយោងលើវិធានទាំងអស់នោះ នៅក្នុងដំណើរការរៀបចំវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក[១៥]។ វិធានទាំងអស់នេះតំណាងឱ្យបទដ្ឋានអន្តរជាតិដែលមាននាពេលបច្ចុប្បន្ន ពាក់ព័ន្ធទៅនឹងរឿងក្តីនានា ដែលតុលាការយកមកប្រើដើម្បីវិនិច្ឆ័យទោសលើឧក្រិដ្ឋកម្មអន្តរជាតិ ហើយវិធានទាំងនេះក៏ស្របតាមកាតព្វកិច្ចរបស់ អ.វ.ត.ក ដូចមានចែងនៅក្នុង មាត្រា ៣៣ ថ្មី នៃច្បាប់ អ.វ.ត.ក ក្នុងការដឹកនាំកិច្ចដំណើរការនីតិវិធី អនុលោមតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរតាមច្បាប់កំណត់ ដូចមានចែងនៅក្នុង មាត្រា ១៤ និង ១៥ នៃកតិកាសញ្ញា ICCPR[១៦]។ ហេតុដូច្នេះ អង្គជំនុំជម្រះសាលាដំបូងឯកភាពតាម អង្គបុរេជំនុំជម្រះ នៅពេលដែលអង្គបុរេជំនុំជម្រះបានកត់សម្គាល់ឃើញថា:

> វិធានផ្ទៃក្នុង...បង្កើតជាប្រព័ន្ធច្បាប់នីតិវិធីមួយដោយខ្លួនឯង ដែលពាក់ព័ន្ធនឹងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក ហើយត្រូវបានអនុម័ត និងមានការយល់ស្របពីកិច្ចប្រជុំពេញអង្គនៃ អ.វ.ត.ក។ វិធានផ្ទៃក្នុងនេះមិនផ្ទុយនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឡើយ ប៉ុន្តែគោលបំណងរបស់ អ.វ.ត.ក ខុសគ្នាជាសំខាន់ពីដំណើរការសាមញ្ញរបស់តុលាការព្រហ្មទណ្ឌកម្ពុជា ដែលតម្រូវឱ្យ អ.វ.ត.ក មានប្រព័ន្ធមួយដែលមានលក្ខណៈពិសេស។ ដូច្នេះ វិធានផ្ទៃក្នុងជាលិខិតូបករណ៍ចំបង ដែលយើងគួរនឹងយកមកពិនិត្យមើល ក្នុងការកំណត់នីតិវិធីនៅចំពោះមុខ អ.វ.ត.ក ក្នុងករណីមានភាពខុសគ្នារវាងនីតិវិធីនៃវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា[១៧]។

៨. ហេតុដូច្នេះ សំណើរបស់ជនជាប់ចោទសុំមោឃភាពវិធានផ្ទៃក្នុងទាំងមូល គឺត្រូវបដិសេធចោល។

៩. សំណើរបស់ នួន ជា សុំមោឃភាពដីកាបង្គាប់ឱ្យរៀបចំ ក៏ត្រូវបដិសេធចោលផងដែរ។ អនុលោមតាមវិធាន ៤៨ កិច្ចស៊ើបសួរ ឬកិច្ចរបស់អង្គជំនុំជម្រះ អាចត្រូវបានចាត់ទុកជាមោឃៈ តែចំពោះករណីកំហុសនីតិវិធីដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិរបស់ភាគីដែលដាក់ពាក្យសុំ

---

[១៥] អញ្ញត្រកម្មរបស់ នួន ជា កថាខណ្ឌ ២១។

[១៦] កិច្ចព្រមព្រៀងបានបង្កើតគោលការណ៍គ្រឹះផ្សេងៗថែមទៀត រួមទាំងសិទ្ធិក្នុងការទទួលបានកិច្ចដំណើរការនីតិវិធីប្រកបដោយយុត្តិធម៌ និងបាប់របស យោងតាមបទដ្ឋានដែលបានបង្កើតឡើងតាមកម្រិតអន្តរជាតិ (សូមមើល ឧទាហរណ៍ កិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា ១៣(១))។

[១៧] សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក នួន ជា ប្រឆាំងនឹងដីកាបដិសេធពាក្យសុំមោឃភាព (សាធារណៈ) ឯកសារ D55/1/8 ចុះថ្ងៃទី ២៦ ខែ សីហា ឆ្នាំ ២០០៨ កថាខណ្ឌ ១៤។

ប៉ុណ្ណោះ។ ក្នុងចំណោមសម្ភារៈដែលត្រូវដាក់ ដីកាបង្គាប់ឲ្យរៀបចំបានតម្រូវឲ្យគ្រប់ភាគីទាំងអស់ដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្នើសុំព័ត៌មានបន្ថែមពាក់ព័ន្ធទៅនឹងបញ្ជីទាំងអស់នេះ និងបញ្ជីឈ្មោះឯកសារ និងវត្ថុតាង។ ដីកាបង្គាប់ឲ្យរៀបចំ ស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តជាអន្តរជាតិពាក់ព័ន្ធជាមួយនឹងរឿងក្តីដែលមានទំហំធំ និងភាពស្មុគស្មាញបែបនេះ។ ដីកាបង្គាប់ឲ្យរៀបចំ ដែលត្រូវបានលើកឡើងដោយជនជាប់ចោទ គឺពាក់ព័ន្ធទៅនឹងផ្នែកដែលតម្រូវឲ្យភាគីនានាដាក់បញ្ជីមួយស្តីពីអង្គហេតុនានាដែលមិនជំទាស់ អនុលោមតាមវិធាន ៨០(៣)(ង)[១៨]។ វិធានដែលគ្រាន់តែតម្រូវឲ្យភាគីដាក់បញ្ជីមួយស្តីពីអង្គហេតុនានាដែលមិនជំទាស់នោះគឺ មានភាពស៊ីសង្វាក់គ្នាជាមួយនឹងការអនុវត្តដែលមាននាពេលបច្ចុប្បន្ននៅតុលាការផ្សេងៗទៀតផង និងធានាសិទ្ធិជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផង។

## ហេតុដូច្នេះ អង្គជំនុំជម្រះ

**ប្រកាសថា** អញ្ញត្រកម្មរបស់ជនជាប់ចោទ គឺមិនអាចទទួលយកបាន។

**ប្រកាសថែមទៀតថា** ខ្លឹមសារនៃអញ្ញត្រកម្មនេះ គឺគ្មានមូលដ្ឋាន។

**បដិសេធ** សំណើរបស់ជនជាប់ចោទសុំមោឃភាពដីកាបង្គាប់ឲ្យរៀបចំ។

ភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C E T C

**និល ណុន**

[១៨] អញ្ញត្រកម្មរបស់ នួន ជា ឧបសម្ព័ន្ធ ក ទំព័រ ក-១។